# របាយការណ៍ប្រចាំខែមេសា ឆ្នាំ ២០១៦ របស់មន្ទីរអភិវឌ្ឍន៍ជនបទ ខេត្តឧត្តរមានជ័យ

## ១. សេចក្តីផ្តើម

ខេត្តឧត្តរមានជ័យស្ថិតនៅទិសឧត្តរនៃព្រះរាជាណាចក្រកម្ពុជា មានចម្ងាយប្រមាណ ៤៤១ គីឡូម៉ែត្រ ពីរាជធានីភ្នំពេញ មានផ្ទៃដីសរុបចំនួន ៦.៦៣១,៧២ គីឡូម៉ែត្រក្រឡា។ ខេត្តនេះមានព្រំប្រទល់ខាងកើតជាប់នឹងខេត្តព្រះវិហារ ខាងលិចជាប់នឹង ខេត្តបន្ទាយមានជ័យ ខាងត្បូងជាប់នឹងខេត្តសៀមរាប និងខាងជើងប្រវែង ២២៥ គីឡូម៉ែត្រជាប់នឹងខេត្តស៊ីសាកេត ខេត្តបុរីរុំ និងខេត្តសុរិន្ទ្រ ប្រទេសថៃ និងមានស្រុកចំនួន ០៤ និងក្រុង ១ គឺស្រុកអន្លង់វែង ស្រុកត្រពាំងប្រាសាទ ស្រុកចុងកាល់ ស្រុកបន្ទាយអំពិល និងក្រុងសំរោង។

## ២. ស្ថានភាពរបស់មន្ទីរ

### ២.១ ការងាររដ្ឋបាល និងបុគ្គលិក

មន្ទីរអភិវឌ្ឍន៍ជនបទខេត្តឧត្តរមានជ័យ ដឹកនាំដោយប្រធានមន្ទីរ ០១ រូប និងអមដោយអនុប្រធានមន្ទីរចំនួន ០២ រូប រួមមាន÷ បុគ្គលិកសរុបចំនួន ៣៤ នាក់ ក្នុងនោះនៅកម្រិតរដ្ឋបាលថ្នាក់មន្ទីរមានការិយាល័យជំនាញចំនួន ០៨ និងថ្នាក់ស្រុក ០៥ ។

### ២.២ កិច្ចប្រជុំផ្សេងៗ និងទំនាក់ទំនងសាធារណៈ:

- ថ្ងៃទី ២២ ខែមីនា មន្ត្រីការិយាល័យរដ្ឋបាល ០១ រូប ចូលរួមកិច្ចប្រជុំពិភាក្សាទៅលើមូលនិធិរាជរដ្ឋាភិបាល ក្នុងកម្មវិធីអភិវឌ្ឍន៍សេដ្ឋកិច្ចតំបន់ (RED III) ក្រោមអធិបតីភាព ឯកឧត្តម **ឈៀង យ៉ាណារ៉ា** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាអគ្គលេខាធិការ គ.ជ.នា នៅសាលាខេត្តឧត្តរមានជ័យ
- ថ្ងៃទី ២៥ ខែមីនា លោកប្រធានមន្ទីរ និងលោកអនុប្រធានមន្ទីរ ចូលរួមក្នុងពិធីក្រុងពាលីបើកការដ្ឋានរៀបចំបង្កើតភូមិស្រះកែវថ្មី ក្រោមអធិបតីភាព ឯកឧត្តម **ស ថាវី** អភិបាលខេត្ត នៅភូមិស្រះកែវ ឃុំចុងកាល់ ស្រុកចុងកាល់
- ថ្ងៃទី ២៦ ខែមីនា លោកអនុប្រធានមន្ទីរ ចូលរួមក្នុងពិធីចែកអំណោយកាកបាទក្រហមកម្ពុជា ក្រោមអធិបតីភាព ឯកឧត្តម **អ៊ុយ សំអាត** នាយកនៃអគ្គនាយកដ្ឋានគ្រប់គ្រងគ្រោះមហន្តរាយកាកបាទក្រហមកម្ពុជា នៅផ្ទះតាម៉ុក ស្រុកអន្លង់វែង
- ថ្ងៃទី ២៧ ខែមីនា លោកអនុប្រធានមន្ទីរ ចូលរួមពិធីបុណ្យចម្រើនព្រះជន្មាយុ ប្រគេនព្រះគ្រូឧត្តរមណី **ប៊ុន សាលួត** ព្រះមេគុណ និងជាព្រះគ្រូឧបជ្ឈាយ៍ខេត្ត ក្រោមអធិបតីភាព ឯកឧត្តម **ស ថាវី** អភិបាលខេត្ត នៅវត្តប្រាសាទរាជាសំរោង
- ថ្ងៃទី ២៨ ខែមីនា លោកអនុប្រធានមន្ទីរ ចូលរួមពិធីអនុសំវច្ឆរៈមហាសន្និបាតមន្ត្រីសង្ឃលើកទី ២៤ ក្រោមអធិបតីភាពឯកឧត្តម **មិន ឃិន** រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា នៅមន្ទីរទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច

- ថ្ងៃទី ២៨ ខែមីនា លោកប្រធានមន្ទីរ ចូលរួមកិច្ចប្រជុំគណៈបញ្ជាការរដ្ឋបាលឯកភាពខេត្ត ក្រោមអធិបតីភាព ឯកឧត្តម **ស ថាវី** អភិបាលខេត្ត នៅសាលាខេត្តឧត្តរមានជ័យ
- ថ្ងៃទី ២៩ ខែមីនា លោកអនុប្រធានមន្ទីរ ចូលរួមសន្និបាតបូកសរុបការងារទេសចរណ៍ ឆ្នាំ២០១៥ និងទិសដៅអនុវត្តបន្តឆ្នាំ ២០១៦ របស់មន្ទីរទេសចរណ៍ខេត្តឧត្តរមានជ័យ ក្រោមអធិបតីភាព ឯកឧត្តម **ស ថាវី** អភិបាលខេត្ត នៅសាលប្រជុំសាខាកាកបាទក្រហមកម្ពុជាខេត្តឧត្តរមានជ័យ
- ថ្ងៃទី ៣១ ខែមីនា លោកអនុប្រធានមន្ទីរ និងមន្ត្រីរដ្ឋបាល ០១ រូប ចូលរួមកិច្ចប្រជុំពង្រឹងភាពជាដៃគូរវាងអង្គការជាតិ អន្តរជាតិជាមួយអាជ្ញាធរខេត្ត ដើម្បីឆ្លុះបញ្ចាំងនូវសកម្មភាពដែលបានអនុវត្តឆ្នាំ ២០១៥ និងទិសដៅសម្រាប់អនុវត្តឆ្នាំ ២០១៦ ក្រោមអធិបភីភាព ឯកឧត្តម **លឹម សុខតូ** អភិបាលរងខេត្ត នៅសាលាខេត្តឧត្តរមានជ័យ
- ថ្ងៃទី ០៤ ខែមេសា លោកអនុប្រធានមន្ទីរ ចូលរួមជាគណៈអធិបតី ក្នុងកម្មវិធីដាក់ដំណើរការគម្រោងថ្មីទទួលផលដោយកសិករចំនួន ១៩០ គ្រួសារ ស្ថិតនៅភូមិគោកចាន់រី សង្កាត់កូនក្រៀល ក្រុងសំរោង និង
- ថ្ងៃទី ០៧ ខែមេសា លោកអនុប្រធានមន្ទីរ ចូលរួមកិច្ចប្រជុំសាមញ្ញលើកទី ២៣ របស់ក្រុមប្រឹក្សាខេត្ត ឆ្នាំទី ២ អាណត្តិទី ២ ក្រោមអធិបតីភាព ឯកឧត្តម **យឹម ធិន** ប្រធានក្រុមប្រឹក្សាខេត្ត នៅសាលាខេត្តឧត្តរមានជ័យ។

## ៣. លទ្ធផលសម្រេចបានតាមវិស័យ

### ៣.១ ការងារផ្លូវជនបទ

- ចុះត្រួតពិនិត្យបញ្ចប់គម្រោងផ្លូវជួសជុលបន្ទាន់ឆ្នាំ ២០១៥ នៅឃុំចុងកាល់ ស្រុកចុងកាល់ និងសង្កាត់កូនក្រៀល ក្រុងសំរោង
- ចុះរកទីតាំងក្រាលគ្រួសក្រហម នៅឃុំចុងកាល់ ដើម្បីផ្គត់ផ្គង់ផ្លូវថែទាំខួបសម្រាប់ឆ្នាំ ២០១៦ និង
- ចុះត្រួតពិនិត្យការងារសាងសង់ផ្លូវថ្មី នៅភូមិបាតថ្កូវ ឃុំចុងកាល់ ស្រុកចុងកាល់ ប្រវែង ៤៤០០ ម៉ែត្រ។

### ៣.២ ការងារផ្គត់ផ្គង់ទឹកស្អាត

- ថ្ងៃទី ៣០ ខែមីនា មន្ត្រីការិយាល័យផ្គត់ផ្គង់ទឹកជនបទ បានសហការណ៍ជាមួយអង្គការប្រាចុះអនុវត្តសកម្មភាពការងារជួសជុលអណ្តូងស្នប់អាហ្វ្រិដេវសម្រេចបានចំនួន១៧អណ្តូងក្នុងភូមិឃុំគោលដៅដូចខាងក្រោម÷
    - ក្រុងសំរោង សង្កាត់សំរោង ០៦ អណ្តូង
    - ក្រុងសំរោង សង្កាត់បុស្សូវ ០៥ អណ្តូង
    - ស្រុកចុងកាល់ ឃុំពង្រ ០១ អណ្តូង
    - ស្រុកចុងកាល់ ឃុំជើងទៀន ០១ អណ្តូង
    - ស្រុកចុងកាល់ ឃុំចុងកាល់ ០២ អណ្តូង

- ស្រុកបន្ទាយអំពិល ឃុំគោកមន ០២ អណ្តូង

- ថ្ងៃទី ១៤-១៥ ខែមីនា មន្ត្រីការិយាល័យផ្គត់ផ្គង់ទឹកជនបទ សហការណ៍ជាមួយអង្គការប្រា ចុះអនុវត្តសកម្មភាពអប់រំនិងផ្សព្វផ្សាយស្តីពីការសាងសង់និងប្រើប្រាស់បង្គន់អនាម័យនៅភូមិសឹង្ហ ឃុំគោកមន។ អ្នកចូលរួមសរុបចំនួន ៥៦ នាក់ ស្រី ៣៨ នាក់។ អង្គការប្រា បានផ្តល់សំភារៈសាងសង់បង្គន់អនាម័យ ៥១ គ្រួសារ និងភូមិទទឹងថ្ងៃ ឃុំបេង ស្រុកបន្ទាយអំពិល មានអ្នកចូលរួមសរុបចំនួន ៣៨ នាក់ ស្រី ២៦ នាក់ អង្គការប្រា បានផ្តល់សំភារៈសាងសង់បង្គន់ អនាម័យចំនួន ៤៧ គ្រួសារ
- ថ្ងៃទី ១០ ខែមេសា ចូលរួមប្រជុំជាមួយគណៈកម្មការគ្រប់គ្រងគ្រោះមហន្តរាយថ្នាក់ខេត្ត(PCDM) ស្តីពីការចុះត្រួតពិនិត្យទំនប់អាងស្ទឹងស្រែង និងរៀបចំផែនការមេសម្រាប់សាងសង់ប្រព័ន្ធទឹកពីអាងស្ទឹងស្រែងតភ្ជាប់មកចែកចាយទូទាំងក្រុងសំរោង ក្រោមអធិបតីភាព ឯកឧត្តម **ញឹម វណ្ណដា** អនុប្រធានទី១គណៈកម្មការគ្រប់គ្រងគ្រោះមហន្តរាយ (NCDM) និង
- ថ្ងៃទី ១៣ ខែមេសា ចូលរួមប្រជុំស្តីពីការរៀបចំដឹកទឹកចែកចាយជូនប្រជាពលរដ្ឋ នៅសង្កាត់អូរស្វាយ ក្រោមអធិបតីភាព ឯកឧត្តម **ស ថាវី** អភិបាលខេត្តឧត្តមានជ័យ។

## ៣.៣ ការងារថែទាំសុខភាពជនបទ

- ថ្ងៃទី០៨ ខែមេសា ចូលរួមកិច្ចប្រជុំស្តីពី ផែនការសម្រាប់ការអនុវត្តកម្មវិធី CLTS ប្រចាំឆ្នាំ២០១៦ នៅសណ្ឋាគារភ្នំប្រុស ខេត្តកំពង់ចាម ក្រោមហិរញ្ញប្បទានថវិការបស់អង្គការ UNICEF ដោយមានការចូលរួមពីមន្ត្រីតំណាងអង្គការ UNICEF ក្រុមការងារ CLTS នៃនាយកដ្ឋានថែទាំ សុខភាពជនបទ និងមន្ត្រីអនុវត្តកម្មវិធីមកពីមន្ទីរអភិវឌ្ឍន៍ជនបទ ទាំង១៣ខេត្តគោលដៅសរុបចំនួន ១៩ នាក់ ស្ត្រី ០៤ នាក់។ លទ្ធផលសម្រេចបាននៃកិច្ចប្រជុំរួមមាន÷
  - មន្ទីរអភិវឌ្ឍន៍ជនបទខេត្ត បានគ្រោងភូមិ ODF ចំនួន ០៩ ភូមិថ្មីបន្ថែមទៀត សម្រាប់ឆ្នាំ ២០១៦
  - អង្គការ Unicef នឹងផ្តល់ជូននូវសម្ភារៈសម្រាប់សាងសង់បង្គន់អនាម័យមួយចំនួនដល់បណ្តាខេត្ត ដែលមានតម្រូវការ និង
  - មន្ទីរអភិវឌ្ឍន៍ជនបទ ទាំង ១១ ខេត្តគោលដៅចាស់ ត្រូវសម្រេចអោយបាននូវកំណើនចំនួនអនាម័យក្នុង ១ ខែ ពី ៣-៥បង្គន់/១ភូមិ នៃភូមិសរុបរបស់ខេត្តនីមួយៗ។

## ៣.៤ ការអភិវឌ្ឍន៍ព្រំដែនទិសខាងជើង និងខាងលិចប្រទេស

**ការងារសាងសង់ផ្ទះ÷**

- **ភូមិតាមាន់សែនជ័យ÷** បានធ្វើការសាងសង់ផ្ទះរួចរាល់ជាស្ថាពរចំនួន **៣៨ ខ្នង** ក្នុងជំហានទី៤ នៅភូមិតាមាន់សែនជ័យ ស្រុកបន្ទាយអំពិល ខេត្តឧត្តរមានជ័យ។

### ៣.៥ ការងារការិយាល័យអភិវឌ្ឍន៍ជនបទ ក្រុង/ស្រុក

- ការិយាល័យអភិវឌ្ឍន៍ជនបទស្រុកបន្ទាយអំពិល
  - ចូលរួមប្រជុំសាមញ្ញលើកទី២២ អាណត្តិទី២ របស់ក្រុមប្រឹក្សាស្រុកបន្ទាយអំពិល
  - ចូលរួមប្រជុំគណៈបញ្ជាការឯកភាពស្រុកបន្ទាយអំពិល។

## ៤. ទិសដៅការងារបន្ត

- រៀបចំផែនការសកម្មភាពសម្រាប់ត្រីមាសទី២ ទី៣ និងទី៤ ឆ្នាំ២០១៦
- សាងសង់អណ្តូងស្នប់អាហ្វ្រីដេវចំនួន ១៧ អណ្តូង
- ជួសជុលអណ្តូងស្នប់អាហ្វ្រីដេវសម្រាប់ជួសជុលចំនួន ១០ អណ្តូង
- សាងសង់ធុងចម្រោះទឹកស្អាតចំនួន ១០០ ធុង
- ចុះសាងសង់ផ្លូវបាតថ្មោ ប្រវែង ៤៤០០ ម៉ែត្រ នៅស្រុកចុងកាល់
- ធ្វើការជួសជុលខ្សែផ្លូវថែទាំលក្ខណៈខួបប្រវែង ១៥ ៥០០ ម៉ែត្រ សម្រាប់ឆ្នាំ ២០១៦ នៅក្រុងសំរោង និង
- ចុះធ្វើបច្ចុប្បន្នភាពខ្សែផ្លូវ។